# ឆ្នាំទាំង១២

## *ឆ្នាំជូត*

*ឆ្នាំជូត ( ធាតុទឹក ពង្សទេវតាប្រុស)*

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំជូត នាម( សត្វកណ្តុរ) ពង្សទេវតាប្រុស ធាតុទឹក តាមទំនាយក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សដែលមានចិត្តក្លាហាន ហ៊ានពុះពារគ្រប់ឧបសគ្គ ចិត្តរឹងមានះ ចូលចិត្តសេពគប់និងឈឺឆ្អាលចំពោះរឿងអ្នកដទៃ តែច្រើនអភ័ព្វដោយសារជួយគេ ហើយបានផលអាក្រក់តបសងវិញ ។ ច្រើនស្វែងរកបាន ដោយកម្លាំងញើសឈាមខ្លួនឯង ។ បើសេពគប់ជាមួយអ្នកធំ ឬនាហ្មឺនរដ្ឋការច្រើនបានផលល្អប្រសើរ បើចេញដំណើរដើរឆ្ងាយនឹងមានមិត្តភក្តិចោមស្រឡាញ់រាប់អាន ហើយមានទីលំនៅមិនសូវពិតប្រាកដ ច្រើនផ្លាស់ប្តូរទីកន្លែង បុគ្គលពួកនេះគួររកស៊ីប្រកបមុខរបរផ្លូវគោក ទើបបានគាប់ប្រសើរ ។

## ឆ្នាំ ឆ្លូវ

ឆ្នាំ ជូត( ធាតុដី ពង្សមនុស្សប្រុស)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំឆ្លូវ នាម( សត្វគោ) ពង្សមនុស្សប្រុស ធាតុដី តាមទំនាយបុរាណលោកបានទាយទុកថា ជាមនុស្សច្រើនអភ័ព្វ កំសត់ នឿយហត់ខាងដើម លុះចុងក្រោយទើបបានល្អគាប់ប្រសើរឡើងវិញ ចូលចិត្តយាត្រាទៅកាន់ទីឆ្ងាយ លាភសក្ការៈច្រើនបានដោយសារអ្នកដទៃ សេពគប់អ្នកធំ ឬនាហ្មឺនរដ្ឋការបានផលមធ្យម បុគ្គលពួកនេះចូលចិត្តប្រកបមុខរបរជួញដូរ ជាមនុស្សចូលចិត្ត និងកាមរោគច្រើន ។

## ឆ្នាំ ខាល

ឆ្នាំ ខាល ( ធាតុឈើ ពង្សយក្សស្រី)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំខាល នាម( សត្វខ្លា) ពង្សយក្សស្រី ធាតុឈើ តាមទំនាយបុ រាណលោកបានទាយទុកមកថា ជាមនុស្សច្រើនអភ័ព្វញាតិការ ជាមនុស្សដែលមានគេច្រណែននិន្ទានិយាយអាក្រក់ពីខ្លួន លាភសក្ការៈច្រើនបានដុំៗ បើធ្វើការនឹងបានមុខតំណែងធំ និងមានគេជួយផ្គួចផ្តើម

បើប្រកបមុខរបររកស៊ីលក់ដូរនឹងបានផលល្អប្រសើរ បុគ្គលពួកនេះពុំសូវចូលចិត្តចរយាត្រាចេញឆ្ងាយទេ។ មានមនុស្សសប្បុរសផ្តល់លាភឱ្យជារឿយៗ ។

# ឆ្នាំ ថោះ

**ឆ្នាំថោះ** ( ធាតុឈើ ពង្សមនុស្សស្រី)

មនុស្សប្រុស-ស្រីណាកើតឆ្នាំថោះ នាម( សត្វទន្សាយ) ពង្សមនុស្សស្រី ធាតុឈើ តាមទំនាយ ក្បួនបុរាណលោបានទាយទុកមកថា ជាមនុស្សដែលមានសន្តានចិត្តទន់ភ្លន់ ចូលចិត្តរាប់អានមេត្រីចំពោះញាតិមិត្តសន្តានដោយស្មោះត្រង់ ជាមនុស្សព្យាយាម អត់ធន់នឹងការលំបាកគ្រប់យ៉ាង លាភសក្ការៈច្រើនរកបានដោយតឹងតែង បើសេពគប់ជាមួយអ្នកធំច្រើនអភ័ព្វខ្លួន បើនឹងប្រកបមុខរបរជួញដូរបានផលល្អល្មមបង្គួរ ។

# ឆ្នាំ រោង

**ឆ្នាំ រោង** ( ធាតុមាស ពង្សទេវតាប្រុស)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំរោងនេះ នាម( សត្វនាគ) ពង្សទេព្តាប្រុស ធាតុមាស តាមទំនាយក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សច្រើនអភ័ព្វញាតិការ ច្រើនមានទុក្ខទោសដោយសារជួយឈឺឆ្អាលក្នុងរឿងអ្នកដទៃ លាភសក្ការៈច្រើនបានដោយសារភរិយា ច្រើនអភ័ព្វកំសត់ពីដំបូង លុះចុងក្រោយទើបបានល្អគាប់ប្រសើរឡើងវិញ ។ បើសេពគប់នាហ្មឺនមន្ត្រីនឹងបានជាធំល្អប្រសើរណាស់ ។

# ឆ្នាំ ម្សាញ់

**ឆ្នាំ ម្សាញ់** ( ធាតុឈើ ពង្សមនុស្សប្រុស)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំម្សាញ់នេះ នាម( ពស់វែក) ពង្សមនុស្សប្រុស ធាតុឈើ តាមក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សច្រើនអភ័ព្វក្នុងការជួយយកអាសារគេ ចូលចិត្តចរចាពាក្យឥតប្រយោជន៏ ធ្វើការងារច្រើនខ្ជីខ្ជា ជាមនុស្សដែលគេមិនសូវអើពើរាប់អាន តែបើសិនជាគេរាប់រករាក់ទាក់នោះ គឺច្បាស់ជាគេសំឡឹងឃើញលាភសក្ការៈអ្វីមួយពីបុគ្គលនេះហើយ ។ បើសេពគប់ជាមួយអ្នកធំនឹងបានផលជាមធ្យម ។

## ឆ្នាំ មមី

**ឆ្នាំ មមី** ( ធាតុភ្លើង ពង្សទេវាស្រី)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំនេះ នាម( សត្វសេះ) ពង្សទេព្តាស្រី ធាតុភ្លើង តាមក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សដែលសំបូរទៅដោយញាតិមិត្តរាប់អានស្រឡាញ់ច្រើន ។ តែមានចិត្តលោភលន់នឹងលាភសក្ការៈផ្សេងៗ ធ្វើដំណើរឆ្ងាយច្រើនកិកកុកនៅតំអក់ក្រោយគេ លាភសក្ការៈច្រើនបានមកពីឆ្ងាយ សេពគប់យកអាសារអ្នកធំច្រើនបានល្អ បើធ្វើការនឹងបានជាធំលើគេទាំងពួង បើប្រកបមុខរបរកស៊ីបានផលល្អបង្គួរ ។

## ឆ្នាំ មមែ

**ឆ្នាំ មមែ** ( ធាតុមាស ពង្សទេព្តាស្រី)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំនេះ នាម( សត្វពពែ) ពង្សទេព្តាស្រី ធាតុមាស តាមក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សមានចិត្តក្លាហាន តែស្លូតបូត សុភាពរាបសារ ធ្វើដំណើរទៅកាន់ទីណាមានគេស្រឡាញ់ចូលចិត្តច្រើន លាភសក្ការៈច្រើនបានដោយសារអ្នកដទៃនាំយកមកឱ្យ ។ បើធ្វើការងារនឹងបានជាធំ បើមានទុក្ខទោសនឹងមានគេជួយយកអាសារ ជាមនុស្សដែលមានអធ្យាស្រ័យល្អចំពោះអ្នកដទៃ ។

## ឆ្នាំ វក

**ឆ្នាំ វក** ( ធាតុដែក ពង្សយក្សប្រុស)

មនុសប្រុស-ស្រីណាដែលកើតឆ្នាំវកនេះ នាម( សត្វស្វា) ពង្សយក្សប្រុស ធាតុដែក តាមក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សវៅហាស៊ីបាន ទៅណាមកណាច្រើនគេរាប់រករាក់ទាក់ លាភសក្ការៈច្រើនបានមកពីចាស់ព្រឹទ្ធាចារ្យ ឬបណ្ឌិតប្រាជ្ញនាំយកមកឱ្យ ។ តែមាត់ចូលចិត្តចរចាតែពីរឿងអ្នកដទៃ ចូលចិត្តលេងញេះញោះឥតប្រយោជន៏ បើសេពគប់អ្នកធំ ឬ នាហ្មឺននឹងបានល្អបង្គួរ បើប្រកបរបរកស៊ីជួញដូរនឹងបានផលល្អណាស់ ។

## ឆ្នាំ វកា

ឆ្នាំ រកា ( ធាតុដែក ពង្សយក្សប្រុស)

មនុសប្រុស-ស្រីណាដែលកើតឆ្នាំរកានេះ នាម( សត្វមាន់) ពង្សយក្សប្រុស ធាតុដែក តាមក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សដែលមានចិត្តស្មោះត្រង់ ក្លាហាន មានប្រាជ្ញាវាងវៃ អាចសំរេចកិច្ចការផងទាំងពួងបានយ៉ាងល្អប្រសើរ តែអភ័ព្វច្រើនមានគេនិយាយអាក្រក់ ច្រណែនឈ្នានីសដល់ខ្លួន លាភសក្ការៈច្រើនមានចាស់ព្រឹទ្ធាចារ្យនាំយកមកឱ្យ លុះក្រោយមកនឹងត្រូវរកបានដោយកម្លាំងប្រាជ្ញាខ្លួនឯង  បើសេពគប់អ្នកធំ ឬអ្នកធ្វើការរដ្ឋនឹងបានល្អបង្គួរ  បើប្រកបរបររកស៊ីលក់ដូរនឹងបានល្អប្រសើរ ។

## ឆ្នាំ ច

ឆ្នាំ ច ( ធាតុដី ពង្សយក្សស្រី)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំចនេះ នាម( សត្វឆ្កែ) ពង្សយក្សស្រី ធាតុដី តាមក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សដែលមានគេនិយមរាប់រក មានគេជួយឈឺឆ្អាលជួយយកអាសារគ្រប់ទីកន្លែង  តែលាភសក្ការៈច្រើនរកបានដោយក្រលំបាកជាខ្លាំង សេពគប់អ្នកធំ នាហ្មឺនមន្ត្រីនឹងបានល្អដោយមានមនុស្សស្រីជួយផ្តួចផ្តើម បើធ្វើការងាររដ្ឋពុំសូវល្អ បើនឹងជួញដូរល្អណាស់ ។

## ឆ្នាំ កុរ

ឆ្នាំ កុរ ( ធាតុទឹក ពង្សមនុស្សស្រី)

មនុស្សប្រុស-ស្រីណាដែលកើតឆ្នាំកុរនេះ នាម( សត្វជ្រូក) ពង្សមនុស្សស្រី ធាតុទឹក តាមក្បួនបុរាណលោកបានទាយទុកមកថា ជាមនុស្សដែលមានភ័យអាសន្ន ដោយសារជួយយកអាសារគេ ជាមនុស្សដែលមានគេស្រឡាញ់រាប់អានច្រើន លាភសក្ការៈច្រើនបានដោយសារមនុស្សស្រីផ្តល់ឱ្យ តែជាមនុស្សចំអៀកខ្ជិលច្រអូសបន្តិច បើធ្វើការនឹងបានបុណ្យសក្តិធំ មានកេរ្តិ៍ឈ្មោះល្បីល្បាញ ។